00378002

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 22/09/2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

001/18-07-2007-ECCC/TC
E1/39

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de réception): 22/09/2009
ម៉ោង (Time/Heure): 11:20
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

## កំណត់ហេតុជាលាយលក្ខណ៍អក្សរ
## នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះករណី "ឌុច"
## សាធារណៈ

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ
ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៩ -ថ្ងៃជំនុំជម្រះទី ៣៤

រៀបចំដោយ: ឌុច ផារី និង Natacha WEXELS-RISER

| <u>កំណត់ហេតុអ្នកចូលរួម</u> |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម ធួ មណី |
| ចៅក្រមបម្រុង៖ ចៅក្រម យូរ ឧត្តរា (បម្រុង) និង ចៅក្រម Claudia FENZ (បម្រុង) |
| ក្រឡាបញ្ជី៖ លោក Crippa MATTEO,លោកស្រី សែ កុលវុឌ្ឍី,កញ្ញា Natacha Wexels-Riser,លោក ឌុច ផារី |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក យ៉េត ចរិយា, លោក Robert Petty, លោក ពេជ្រ សម្បត្តិ លោក Zachery Lampell,លោក ប៉ាក់ ចន្ទលីណូ |
| ជនជាប់ចោទ៖ លោក កាំង ហ្គេចអ៊ាវ ហៅ ឌុច |

| |
|---|
| មេធាវីជនជាប់ចោទ៖ លោក ការ សាវុត្ថ, លោក François Roux(អវត្តមាន), លោកស្រី Heleyn Unac,លោក ចាន់ រ៉ាវុធ, កញ្ញា Lucile NATTIEZ |
| មេធាវីដំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ កញ្ញា Silke Studzinsky, កញ្ញា ម៉ុច សុវណ្ណារី, កញ្ញា ទី ស្រ៊ីនណា, លោក គឹម ម៉េងឃី,លោក យ៉ុង ផានិត,លោក ហុង គឹមសួន,លោក Alain Werner, កញ្ញា Jessica Finelle, |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក វ កែវរតនៈ លោក សាន រាដា លោក អ៊ុច អារុណ |
| ផ្សេងៗ៖ |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃ ២៩ មិថុនា ២០០៩ | ចាប់ផ្តើមម៉ោង៖ ៩.00 | បញ្ចប់ម៉ោង៖ ១៥.៥0 |
| សម្រាកព្រឹក | ចាប់ផ្តើមម៉ោង៖១០.៤០ | បញ្ចប់ម៉ោង៖ ១១.00 |
| សម្រាក | ចាប់ផ្តើមម៉ោង៖១២.00 | បញ្ចប់ម៉ោង៖ ១៣.៣០ |
| សម្រាកល្ងាច | ចាប់ផ្តើមម៉ោង៖ ១៤.៤៥ | បញ្ចប់ម៉ោង៖ ១៥.00 |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ៤ ម៉ោង ៥០ នាទី |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| សេចក្តីសម្រេចផ្ទាល់មាត់អំពីការដកសាក្សីចេញពីបញ្ជីឈ្មោះសាក្សី | អង្គជំនុំជម្រះ | ៩.០៣ | ៩.២៤ |
| សំណើររបស់សហព្រះរាជអាជ្ញាទាក់ទងនិងសកម្មឧក្រិដ្ឋកម្មរួម | អង្គជំនុំជម្រះ | ៩.២៥ | ៩.២៧ |
| ការសួរសំនួរដល់សាក្សីដែលជាអ្នករស់រានមានជីវិត KW-01 វ៉ាន់ ណាត ទាក់ទងនិងប្រតិបត្តិការ ស២១ | អង្គជំនុំជម្រះ | ៩.២៨ | ១.៥៣ |
| ការសួរសំនួរដល់សាក្សីដែលជាជនរស់រានមានជីវិត KW-01 វ៉ាន់ ណាត ទាក់ទងនិងប្រតិបត្តិការ ស២១ | សហព្រះរាជអាជ្ញា | ១.៥៣ | ១.២១ |

កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី- ២៩ មិថុនា ២០០៩ /សាធារណៈ

| | | | |
|---|---|---|---|
| សំណើរសុំបង្ហាញខ្សែភាពយន្តចំនួន ២ ថត ដោយជនជាតិវៀតណាម និង ការបដិសេធ | សហព្រះរាជអាជ្ញា | ១៤.២២ | ១៤.២៦ |
| សំណើរសុំប្រើប្រាស់ពេលវេលាដែលនៅសល់សម្រាប់សួរសំនួរដោយមេធាវីដំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីការពារក្តី | មេធាវីដំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ២ | ១៤.២៧ | ១៤.៣១ |
| ការសួរសំនួរដល់សាក្សីដែលជាជនរស់រានមានជីវិត KW-01 វ៉ាន់ ណាត ទាក់ទងនិងប្រតិបត្តិការ ស២១ និង ជើងឯក | មេធាវីដំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្រុម៤ ក្រុម៣ ក្រុម២ និងក្រុម១ | ១.៣១ | ១៥.២៩ |
| ការសួរសំនួរដល់សាក្សីដែលជាជនរស់រានមាន ជីវិត KW-01 វ៉ាន់ ណាត ទាក់ទងនិងប្រតិបត្តិការ ស២១ និង ជើងឯក | មេធាវីការពារជនជាប់ចោទ | ៣.៣០ | ៣.៤៤ |
| ការសួរសំនួរដល់សាក្សីដែលជាអ្នករស់រានមានជីវិត KW-01 វ៉ាន់ ណាត ទាក់ទង និងប្រតិបត្តិការ ស២១ | អង្គជំនុំជម្រះ | ១៥.៤៤ | ១៤.៤៧ |
| សំណើរសំពេលវេលាបន្ថែម និង ការបដិសេធ | មេធាវីដំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ២ និង អង្គជំនុំជម្រះ | ១៥.៤៧ | ១៥.៤៨ |

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**សេចក្តីសម្រេចផ្ទាល់មាត់អំពីការដកសាក្សីចេញពីបញ្ជីឈ្មោះសាក្សី**

- អង្គជំនុំជម្រះប្រកាសនូវសេចក្តីសម្រេចអំពីការដកនូវសាក្សីចេញពីបញ្ជីឈ្មោះសាក្សី



TRIAL CHAMBER CHAMBRE DE PREMIERE INSTANCE E.C.C.C. C.E.T.C.

- សហព្រះរាជអាជ្ញាបានផ្តល់យោបល់ថា ទាក់ទងនិងសាក្សី KW-24 សវនាការអាចធ្វើជាលក្ខណៈ អសាធា ឬ ឲ្យភាគីដាក់សារណាជាលាយលក្ខអក្សរនៅត្រឹមថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៩ ។

**សេចក្តីសង្ខេបទាក់ទងនិងសំណើរបស់សហព្រះរាជអាជ្ញាទាក់ទងនិងសហកម្មឧក្រិដ្ឋកម្មរួម**

អង្គជំនុំជម្រះកត់សម្គាល់នូវការដាក់ឯកសាររបស់សហព្រះរាជអាជ្ញា ដែលបានធ្វើឡើងនៅថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០០៩ ដែលឯកសារនោះបានស្នើសុំដល់អង្គជំនុំជម្រះឲ្យ (ទីមួយ) ធ្វើការប្រកាសថា សញ្ញាណគត្តិយុត្តិនៃ "សហកម្មឧក្រិដ្ឋកម្មរួម" ក្នុងទំរង់ចំនួន៣ គឺអាចយកមកអនុវត្តនៅចំពោះមុខ អ.វ.ត.ក និង (ទីពីរ) សុំឲ្យអនុវត្តនូវសញ្ញាណគត្តិយុត្តិនេះក្នុងសាលក្រមរបស់ខ្លួន ទាក់ទងនិងការប្រព្រឹត្តបទល្មើស ដែលបានចោទប្រកាន់មកលើជនជាប់ចោទ និងការទទួលខុសត្រូវរបស់គាត់ក្នុងនាមជាអ្នកចូលរួមក្នុងសហកម្មឧក្រិដ្ឋកម្មរួម ។

អង្គជំនុំជម្រះបានរំលឹកឡើងវិញថា សហព្រះរាជអាជ្ញាបានចង្អុលបង្ហាញនូវចេតនារបស់ខ្លួន ដែលពឹកផ្អែកលើសញ្ញាណនៃសហកម្មឧក្រិដ្ឋកម្មរួមក្នុងអំឡុងពេល សវនាការបឋម ។ អង្គជំនុំជម្រះរំលឹកឡើងវិញថា យោងតាមវិធាន ៩៨(២) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះអាច "ផ្លាស់ប្តូរការកំណត់បទចោទដែលបានចោទប្រកាន់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះបាន ប៉ុន្តែមិនអាចបញ្ចូលនូវធាតុផ្សំថ្មីនៃបទចោទបានឡើយ" ។

ដូច្នេះហើយអង្គជំនុំជម្រះយល់ឃើញថា បញ្ហានៃទំរង់នៃការទទួលខុសត្រូវរបស់ជនជាប់ចោទ ដោយរួមបញ្ចូលក្នុងនាមជាអ្នកចូលរួមម្នាក់ក្នុងសហកម្មឧក្រិដ្ឋកម្មរួម គឺបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ហើយសូមស្នើសុំដល់ភាគីទាំងអស់ឲ្យដាក់នូវសារណាទាក់ទងនិងសំណើររបស់សហព្រះរាជអាជ្ញា ដោយត្រូវធ្វើឡើងយោងតាមការណែនាំអនុវត្ត និងបន្ទាប់ពីបានទទួលនូវការជូនដំណឹងពីភាសារដែលភាគីបានស្នើសុំ ។

ជាចុងក្រោយ អង្គជំនុំជម្រះបញ្ជាក់ថា ក្នុងដំណាក់កាលនេះ អង្គជំនុំជម្រះកំពុងពិចារណាដោយចេញនូវសេចក្តីសម្រេចទាក់ទងនិងបញ្ហានេះក្នុងពេលជាមួយគ្នានិងការចេញសាលក្រមលើអង្គសេចក្តី ។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C. C.E.T.C.

**ការស្តាប់ចម្លើយសាក្សីដែលជាអ្នករស់រានមានជីវិត KW-01 វ៉ាន់ ណាត ទាក់ទងនិង ប្រតិបត្តិការ ស ២១**

អង្គជំនុំជម្រះតាំងសំនួរដល់សាក្សីទាក់ទងនិងអង្គហេតុ ប្រតិបត្តិការ ស ២១ មានដូចជា៖

- ប្រវត្តិនៃការចាប់ខ្លួនសាក្សី
- ស្ថានភាពនៃការរស់នៅ នៅ ស ២១
- ការចាត់តាំងឲ្យគូររូប
- ការងារគូររូប
- ការពន្យល់លើរូបគំនូរ
- ការរួចផុតពី ស ២១

**ការសួរសំនួរដល់សាក្សីដែលជាអ្នករស់រានមានជីវិត KW-01 វ៉ាន់ ណាត ទាក់ទងនិង ប្រតិបត្តិការ ស ២១**

សហព្រះរាអាជ្ញាតាំងសំនួរដល់សាក្សី KW-01 វ៉ាន់ ណាត ទាក់ទងនិងប្រតិបត្តិការ ស ២១ និង ជើង ឯក មានដូចជា៖

- ស្ថានភាពរស់នៅនៅ ស ២១
- ការចាប់បញ្ជូនទៅ ស ២១

**ការសួរសំនួរដល់សាក្សីដែលជាអ្នករស់រានមានជីវិត KW-01 វ៉ាន់ ណាត ទាក់ទងនិង ប្រតិបត្តិការ ស ២១**

មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម៤ ក្រុម៣ ក្រុម២ និងក្រុម១ តាំងសំនួរដល់សាក្សី។

| កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧.៣ | | | | |
|---|---|---|---|---|
| លេខយោង | លេខយោង | ឈ្មោះ/ការអធិប្បាយ | ចំណាត់ថ្នាក់ឯកសារ( | កំណត់[illegible] |



TRIAL CHAMBER CHAMBRE DE PREMIERE INSTANCE
E.C.C.C

00378007



| របស់អជស ដ | របសកសចស | | សំងាត់បំផុត សំងាត់ ឬសាធារណៈ:) | |
|---|---|---|---|---|
| E3/384 | D28/9 | កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ាន់ ណាត | សាធារណៈ: | 00163735-00163755<br>00163714-00163734<br>00163721-00163734<br>លុបពត៌មានទាក់ទងនិងបុគ្គល |
| E3/249 | D69-An A-P0143 | រូបគំនូរគូរដោយអ្នកទោស វ៉ាន់ ណាត ដែលពិពត៌នាអំពីអ្នកទោសម្នាក់ជាប់ឃុំក្នុងបន្ទប់រួម | សាធារណៈ: | P00000027-00000027<br>មានក្នុង E3 Folder រួចហើយ |
| E3/250 | D69- An A-P0143 | រូបគំនូរ អ្នកទោសជាប់ក្នុងបន្ទប់ នៅមន្ទីរ ស ២១ គូរដោយអ្នកទោស វ៉ាន់ ណាត (រូបគាត់ផ្ទាល់) | សាធារណៈ: | P00000026-00000026<br>មានក្នុង E3 Folder រួចហើយ |
| E3/251 | D69- An A, P0142 | រូបគំនូររបស់អ្នកទោស ស ២១ ឈ្មោះ វ៉ាន់ ណាត ដែលបង្ហាញពីកម្មាភិបាលដកហូតយកកុមារចេញពីម្តាយ | សាធារណៈ: | P00000022-00000022<br>មានក្នុង E3 Folder រួចហើយ |
| E3/252 | D60- An A, P0143 | រូបគំនូររបស់អ្នកទោស ស ២១ ឈ្មោះ វ៉ាន់ ណាត ដែលពិពត៌នាអំពីអ្នកទោសត្រូវបានគេធ្វើទារុណកម្មដោយការស្រោយទឹក | សាធារណៈ: | P00000031-0000001<br>មានក្នុង E3 Folder រួចហើយ |

| | | | | |
|---|---|---|---|---|
| E3/253 | D69-An A, P0143 | រូបគំនូររបស់អ្នកទោស ស ២១ ឈ្មោះ វ៉ាន់ ណាត ដែលពិពណ៌នាអំពីអ្នកទោសត្រូវបានគេធ្វើទារុណកម្មដោយការជ្រមុជទឹក | សាធារណៈ | P00000032-00000032 មានក្នុង E3 Folder រួចហើយ |
| E3/254 | D69- An A-P0143 | រូបគំនូររបស់ វ៉ាន់ ណាត បង្ហាញពីការធ្វើទារុណកម្មដោយធ្វើយ៉ាងណាអោយអ្នកទោសលង់ទឹក | សាធារណៈ | P00000033-00000033 មានក្នុង E3 Folder រួចហើយ |
| E3/255 | D69- An A-P0143 | រូបគំនូររបស់ វ៉ាន់ ណាត បង្ហាញពីការធ្វើទារុណកម្មដោយការប្រើដង្កាប់និងសត្វល្អិត។ | សាធារណៈ | P00000030-00000030 មានក្នុង E3 Folder រួចហើយ |
| E3/256 | D69- An A-P0143 | រូបគំនូររបស់ វ៉ាន់ ណាត បង្ហាញពីការធ្វើទារុណកម្មដោយការប្រើដង្កាប់ | សាធារណៈ | P00000025-00000025 មានក្នុង E3 Folder រួចហើយ |
| E3/257 | D69- An A-P0143 | រូបគំនូររបស់ វ៉ាន់ ណាត បង្ហាញពីការធ្វើទារុណកម្មលើអ្នកទោសដោយការវាយនឹងរំពាត់ | សាធារណៈ | P00000023-00000023 មានក្នុង E3 Folder រួចហើយ |

| | | | | |
|---|---|---|---|---|
| E3/258 | D69- An A-P0143 | រូបគំនូររបស់ វ៉ាន់ ណាត បង្ហាញពីអ្នកទោសត្រូវបានទទួលរងនូវទារុណកម្មឬសំលាប់ | សាធារណៈ: | P00000028-00000028 មានក្នុង E3 Folder រួចហើយ |
| E3/260 | D69- An A-P0143 | រូបគំនូររបស់ វ៉ាន់ ណាត បង្ហាញពីការធ្វើទារុណកម្មលើអ្នកទោសនៅមុខមន្ទីរស-២១ | សាធារណៈ: | 00000029-00000029 មានក្នុង E3 Folder រួចហើយ |
| E3/261 | D69- An A-P0143 | រូបគំនូររបស់ វ៉ាន់ ណាត បង្ហាញពីអ្នកទោសត្រូវបានធ្វើទារុណកម្មដោយការចាប់ចងហើយវាយ | សាធារណៈ: | 00000024-00000024 មានក្នុង E3 Folder រួចហើយ |
| E3/232 | D45/1/2 | សៀវភៅរូបថតដែលក្នុងនោះមានរូបថតមួយចំនួនត្រូវបានយកមកប្រើដើម្បីធ្វើការបង្ហាញដោយ Zoran Lesic | សម្ងាត់ | 00195373-00195377<br>00189128-00189130<br>00360015-00360100<br>មានក្នុង E3 Folder រួចហើយ |
| E3/385 | D2-11 | កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ាន់ ណាត | សាធារណៈ: | 00146810-00146812 |
| E3/386 | IS 4.45 | សៀវភៅដែលរៀបរៀងដោយ វ៉ាន់ ណាត មានចំណងជើងថា: "រូបភាពមន្ទីរឃុំឃាំងប្រ | សាធារណៈ: | 00323452-00323472<br>00106023-00106055 |



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C. C.E.T.C.

| | | | | |
|---|---|---|---|---|
| | | ទេសកម្ពុជា” | | |
| | | | | |

ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖

- **សេចក្តីសម្រេចផ្ទាល់មាត់ស្តីពីការលុបចោលសាក្សីមួយចំនួនចេញពីបញ្ជីឈ្មោះសាក្សី**

អង្គជំនុំជម្រះសាលាដំបូងសូមជូនដំណឹងដល់ភាគីនានា និងសាធារណជនអំពីបញ្ហាដែលបានពិភាក្សានៅក្នុងកិច្ចប្រជុំរៀបចំសវនាការ និងសេចក្តីសម្រេចដែលត្រូវចេញបន្ទាប់ពីកិច្ចប្រជុំនេះ។ ដើម្បីធានាឱ្យការជំនុំជម្រះប្រព្រឹត្តទៅដោយយុត្តិធម៌ និងឆាប់រហ័ស អង្គជំនុំជម្រះបានពិនិត្យមើលឡើងវិញនូវបញ្ជីឈ្មោះសាក្សីក្នុង គោលបំណងកាត់បន្ថយចំនួនសាក្សីដែលត្រូវកោះហៅ។

ក្រោយពីបានពិនិត្យមើលការវិវឌ្ឍន៍នៃការជំនុំជម្រះរហូតមកទល់ពេលបច្ចុប្បន្ន នៅក្នុងកិច្ចប្រជុំរៀបចំការ អង្គជំនុំជម្រះសាលាដំបូងបានស្នើសុំឱ្យមានការកាត់បន្ថយសាក្សីមួយចំនួនចេញពីបញ្ជីឈ្មោះសាក្សី ដោយបញ្ជាក់ថាកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីទាំងនោះដែលបានធ្វើក្នុងអំឡុងពេលនៃដំណាក់កាលស៊ើបអង្កេតនៅចំពោះមុខអ.វ.ត.ក នឹងត្រូវយកពិភាក្សាដេញដោលនៅចំពោះមុខតុលាការ។ អង្គជំនុំជម្រះបានស្នើសុំមតិយោបល់របស់ភាគីនានាទាក់ទងនឹងសំណើនេះ និងបានសួរថាតើមានភាគីណាមួយចង់ឱ្យសាក្សីដែលបានស្នើសុំដកចេញពីបញ្ជីមកផ្តល់សក្ខីកម្មដោយផ្ទាល់ដែរឬទេ។

ឆ្លើយតបនឹងបញ្ហានេះ សហព្រះរាជអាជ្ញា មិនបានផ្តល់មតិយោបល់លើសាក្សីនីមួយៗនោះទេ ប៉ុន្តែបានស្នើសុំបញ្ចូលសាក្សីទាំងនោះក្នុងបញ្ជីឈ្មោះសាក្សីបម្រុងមួយសម្រាប់ពិចារណានៅពេលក្រោយ។ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ក្រុម៣ និងក្រុម៤ គាំទ្រការលើកឡើងរបស់សហព្រះរាជអាជ្ញា។ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម៤ បានស្នើសុំឱ្យកោះហៅសាក្សី KW-12, KW-13, KW-14, KW-18, KW-19 និងKW-28 ប៉ុន្តែដើមបណ្តឹងរដ្ឋប្បវេណីក្រុម៤នេះ មិនបានផ្តល់មូលហេតុសម្រាប់ការ



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C. C.E.T.C.

សំណើសុំរបស់ខ្លួនទេ។

ដើមបណ្តឹងរដ្ឋប្បវេណីក្រុម២ បានស្នើសុំឱ្យកោះហៅសាក្សីKW-13, KW-18, KW-25, CP2/6, KW-28, CP2/4 និងCP2/1។

ក្រុមមេធាវីការពារក្តីបានយល់ស្របជាមួយនឹងការលើកឡើងរបស់អង្គជំនុំជម្រះ លើកលែងតែការស្នើសុំដកលោក Raoul Marc Jennar ចេញពីបញ្ជីសាក្សីតែប៉ុណ្ណោះ។ អង្គជំនុំជម្រះកត់សម្គាល់ថា ក្រុមមេធាវីការពារក្តីមិនស្វែងរកឱ្យមានវត្តមានរបស់សាក្សីទាំងនេះក្នុងគោលបំណងនៃការតទល់គ្នានោះទេ។

ជាសង្ខេប មូលហេតុដែលបានលើកឡើងដោយភាគីនានាគឺ៖
KW-13 គឺស្ថិតក្នុងកងពិសេស និងបានចាប់ខ្លួនប្រជាជន ដែលក្នុងនោះមានជនជាតិចិនផងដែរ។ ជនជាប់ចោទបានប្រកែកចំពោះការលើកឡើងថា ក្រុមនេះពាក់ព័ន្ធនឹងការចាប់ខ្លួនមនុស្ស។

KW-18 នឹងផ្តល់សក្ខីកម្មថា ជនជាប់ចោទបានធ្វើការសួរចម្លើយជាពិសេសដោយផ្ទាល់លើជនបរទេស និងអ្នកទោសសំខាន់ៗ។ សក្ខីកម្មនេះត្រូវបានជនជាប់ចោទបដិសេធ។
KW-25 នឹងផ្តល់សក្ខីកម្មអំពីការជួបប្រជុំរវាងជនជាប់ចោទ និងថ្នាក់លើ ដែលសក្ខីកម្មនេះត្រូវបានជនជាប់ចោទបដិសេធ។

CP2/6 នឹងផ្តល់សក្ខីកម្មអំពីទស្សនកិច្ចរបស់ជនជាប់ចោទនៅជើងឯក។ ជាថ្មីម្តងទៀត សក្ខីកម្មនេះត្រូវបានជនជាប់ចោទបដិសេធ។

KW-28 នឹងផ្តល់សក្ខីកម្មថា ជនជាប់ចោទបានបញ្ជាឱ្យចាប់ខ្លួន និងបានបញ្ជាអោយធ្វើទារុណកម្មក្រោយឆ្នាំ១៩៧៨ ដែលសក្ខីកម្មនេះនឹងបង្ហាញថា ការលើកឡើងរបស់ជនជាប់ចោទដែលថា គាត់ស្អប់ការងាររបស់គាត់ និងភ័យខ្លាចអំពីជោគវាសនារបស់ខ្លួន គឺជាការលើកឡើងមិនគួរឱ្យជឿ។

CP2/4 នឹងផ្តល់សក្ខីកម្មអំពីស្ថានភាពរបស់បុគ្គលិក និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅស-២៤។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C. C.E.T.C.

CP2/1 នឹងផ្តល់សក្ខីកម្មអំពីទំនាក់ទំនងដោយផ្ទាល់រវាងជនជាប់ចោទ និងកងពលធំលេខ២ និងផ្តល់ភស្តុតាងអំពីពេលវេលាក្រោយការដួលរលំរបបខ្មែរក្រហម។

លោក Raoul Marc Jennar គឺជាអ្នកស្រាវជ្រាវអំពីឧក្រិដ្ឋកម្មនានានៅក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ និងបានទស្សនកិច្ចគុកចំនួន១៨៦។ ហេតុដូចនេះ សាក្សីនេះអាចធ្វើការប្រៀបធៀបគុកទាំងនោះជាមួយនឹងស-២១ បាន។ បន្ថែមពីលើនេះ វាមិនយុត្តិធម៌នោះទេ ប្រសិនបើមិនអនុញ្ញាតឲ្យក្រុមមេធាវីការពារក្តីអញ្ជើញអ្នកជំនាញមកផ្តល់សក្ខីកម្មក្នុងតុលាការ។

**សេចក្តីសម្រេច÷**

១. អង្គជំនុំជម្រះកត់សម្គាល់ថា នៅក្នុងអំឡុងកិច្ចប្រជុំរៀបចំសវនាការ គ្មានភាគីណាមួយជំទាស់នឹងការដកសាក្សីខាងក្រោមនេះចេញពីបញ្ជីឈ្មោះសាក្សី និងកំណត់ហេតុស្នូរចម្លើយជាលាយលក្ខណ៍អក្សរដែលធ្វើឡើងចំពោះមុខអ.វ.ត.ក ក្នុងអំឡុងពេលនៃដំណាក់ស៊ើបអង្កេត ដែលបានលើកឡើងចំពោះមុខតុលាការដោយអនុលោមតាមវិធាន៨៧(៣)។ នៅក្នុងករណីគ្មានការជំទាស់ពីភាគីនានា អង្គជំនុំជម្រះយល់ឃើញថា ភាគីនានាមិនបានស្នើសុំឲ្យសាក្សីខាងក្រោមនេះបង្ហាញខ្លួនដោយផ្ទាល់នៅក្នុងតុលាការ៖

KW-16

KW-17

CP2/7

Nic Dunlop

KW-27

KW-06

CP2/10

តើមានការជំទាស់ណាមួយដែលអង្គជំនុំជម្រះមិនទាន់បានដឹង ទាក់ទងនឹងសាក្សីទាំងនេះដែរឬទេ? ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចលុបចោលសាក្សីទាំងនេះចេញពីបញ្ជីឈ្មោះសាក្សី។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C. C.E.T.C.

២. អង្គជំនុំជម្រះកត់សម្គាល់ថា ដើមបណ្តឹងរដ្ឋប្បវេណីក្រុម២ បានដកការស្នើសុំក្នុងការកោះហៅសាក្សីCP2/2 និងCP2/3។ អង្គជំនុំជម្រះសម្រេចមិនកោះហៅសាក្សីទាំងនេះទេ។

៣. អង្គជំនុំជម្រះសម្រេចបដិសេធចំពោះសំណើរបស់៖

-ដើមបណ្តឹងរដ្ឋប្បវេណីក្រុម២ ស្នើសុំឱ្យកោះហៅសាក្សីKW-13, KW-18, KW-25, CP2/6, CP2/4 និងCP2/1។

-ដើមបណ្តឹងរដ្ឋប្បវេណីក្រុម៤ ស្នើសុំឱ្យកោះហៅសាក្សីKW-12, KW-13, KW-14, KW-18 និងKW-19។

**មូលហេតុ៖**

អង្គជំនុំជម្រះបានពិចារណាលើបញ្ជីឈ្មោះសាក្សី និងយល់ឃើញថា សាក្សីមួយចំនួននឹងផ្តល់សក្ខីកម្មស្រដៀងគ្នា ទៅលើអង្គហេតុពាក់ព័ន្ធ។ ដូច្នេះ អង្គជំនុំជម្រះបានជ្រើសរើសយកសាក្សីមួយក្រុមដែលនឹងផ្តល់សក្ខីកម្មដោយផ្ទាល់លើអង្គហេតុដែលពាក់ព័ន្ធបំផុត។ ភាគីទាំងឡាយគួរចងចាំថារាល់ការផ្តល់ចម្លើយទាំងអស់ដែលបានធ្វើឡើងអំឡុងពេលនៃដំណាក់កាលស៊ើបសួរនៅចំពោះមុខ អ.វ.ត.ក នឹងត្រូវយកមកពិភាក្សានៅចំពោះមុខអង្គជំនុំជម្រះទៅតាមពេលវេលាសមស្រប។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសម្រេចលុបចោលសាក្សី KW-12, KW-13, KW-14, KW-18, KW-19, KW-25, CP2/6 និង CP2/4 ចេញពីបញ្ជីឈ្មោះដែលត្រូវកោះហៅចូលតុលាការ។

អង្គជំនុំជម្រះសូមជម្រាបដល់ភាគីនានាឱ្យបានជ្រាបថា បន្ទាប់ពីមានការពិចារណាបន្ថែមអង្គជំនុំជម្រះបានសម្រេចរក្សាទុកសាក្សី KW-28 នៅក្នុងបញ្ជីតទៅទៀតដោយហេតុថា សាក្សីរូបនេះអាចផ្តល់សក្ខីកម្មទៅលើអង្គហេតុពាក់ព័ន្ធនឹងព្រៃស។

អង្គជំនុំជម្រះពិចារណាឃើញថាវាជាការពុំចាំបាច់ដែលត្រូវរក្សាទុកបញ្ជីសាក្សីបម្រុង ដែលសាក្សីអាចត្រូវបានអញ្ជើញឱ្យមកផ្តល់សក្ខីកម្មដោយផ្ទាល់មាត់នោះទេ។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C. C.E.T.C.

៤. នៅថ្ងៃព្រហស្បត្តិ៍ ទី២៥ ខែមិថុនា អង្គជំនុំជម្រះបានជូនដំណឹងភាគីនានាថា ខ្លួនមានបំណង លុបចោលសាក្សីបន្ថែមមួយរូបទៀតគឺ KW-24 ចេញពីបញ្ជីឈ្មោះសាក្សី ហើយភាគីទាំងឡាយនឹង មានឱកាសផ្តល់គំនិត យោបល់ទៅលើសំណើនេះក្នុងថ្ងៃនេះ។
តើមានការយល់ឃើញបែបណាមួយ ទៅលើសំណើលុបចោលសាក្សី KW-24 ចេញពីបញ្ជីឈ្មោះ សាក្សីដែរឬទេ?

*[អង្គជំនុំជម្រះសម្រេចលុបចោលសាក្សី KW-24 ចេញពីបញ្ជីឈ្មោះសាក្សី។ សាក្សីមួយរូបទៀត នឹងផ្តល់សក្ខីកម្ម ទៅលើអង្គហេតុដែល KW-24 នឹងធ្វើការឆ្លើយបំភ្លឺ ដូច្នេះសក្ខីកម្មរបស់ KW-24 នឹងមានលក្ខណៈដដែលៗ។]*

៥. បន្ថែមពីលើនេះ អង្គជំនុំជម្រះមានបំណងជូនដំណឹងភាគីនានា អំពីសេចក្តីលម្អិតផ្នែកបច្ចេក ទេសដូចខាងក្រោម៖

អង្គជំនុំជម្រះនឹងស្តាប់ចម្លើយ៖

- KW-10 សម្រាប់រយៈពេល១ថ្ងៃកន្លះ
- David Chandler សម្រាប់រយៈពេល១ថ្ងៃ
- KW-23 សម្រាប់រយៈពេលកន្លះថ្ងៃ
- CP2/5 សម្រាប់រយៈពេលកន្លះថ្ងៃ
- KW-34 និង Françoise Sironi-Guilbaud រួមគ្នាសម្រាប់រយៈពេល១ថ្ងៃកន្លះ

អង្គជំនុំជម្រះនឹងស្តាប់ចម្លើយ Françoise Siron-Guilbaud ដោយផ្ទាល់ និងស្តាប់ចម្លើយ Richard J. Goldstone and Stéphane Hessel តាមរយៈការផ្តល់សក្ខីកម្មពីចម្ងាយ (video-conference)។

អង្គជំនុំជម្រះពុំទទួលយកសេចក្តីស្នើសុំរបស់មេធាវីការពារក្តី ក្នុងការផ្តល់ឱកាសដល់ខ្លួន និងសហ ព្រះរាជអាជ្ញា ដើម្បីអង្គុយក្បែរសាក្សីដែលផ្តល់សក្ខីកម្មពីចម្ងាយនោះឡើយ។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C. C.E.T.C.

អង្គជំនុំជម្រះសូមឆ្លៀតឱកាសនេះ ជូនដំណឹងដល់ភាគីនានាឲ្យបានជ្រាបថាលោក Charles Figley បានបដិសេធការអញ្ជើញឲ្យមកធ្វើសក្ខីកម្ម ហើយអង្គជំនុំជម្រះពុំមានផែនការបង្ខំលោកឲ្យចូលមកបង្ហាញខ្លួនឡើយ។

- អង្គជំនុំជម្រះសម្រេចផ្តល់ឲ្យភាគីត្រឹមម៉ោង ១៦.០០ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៩ ក្នុងការដាក់នូវសេចក្តីសន្និដ្ឋានទាក់ទងនិងសាក្សី KW-24 ។
- បង្គាប់ឲ្យនាំជនជាប់ចោទទៅមន្ទីរឃុំឃាំង និងនាំគាត់ត្រឡប់មកវិញនៅថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០០៩ ។

ដីកាសម្រាប់ការលើកវារកាលសវនាការ

- សវនាការនឹងបន្តទៅថ្ងៃអង្គារ ទី ៣០ ខែ មិថុនា ឆ្នាំ ២០០៩ វេលាម៉ោង ៩.០០ ព្រឹក ។

ភ្នំពេញ ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៩

ក្រឡាបញ្ជី ក្រឡាបញ្ជី

ឌុច ផា Natacha WEXELS-RISER